ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៧៤៣ ព.ណ.គ.ព.

ថ្ងៃពុធ ១រោជ ខែផល្គុន ឆ្នាំម្សាញ់ ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា ភ្នាក់ងារជំរុញពាណិជ្ជកម្មវៀតណាម នឹងរៀបចំពិព័រណ៍ «The 35th Vietnam International Trade Fair (VIETNAM EXPO 2026)» ពីថ្ងៃទី៨-១១ ខែមេសា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌលពិព័រណ៍អន្តរជាតិវៀតណាម ទីក្រុងហាណូយ ប្រទេសវៀតណាម។ ពិព័រណ៍នេះ គឺជាព្រឹត្តិការណ៍ប្រចាំឆ្នាំ ដែលគាំទ្រដោយក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម ដើម្បីជំរុញការនាំចេញ ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងជំរុញកិច្ចសហការរវាងប្រទេសវៀតណាម និងប្រទេសជាដៃគូ។ គណៈកម្មការរៀបចំពិព័រណ៍ សូមអញ្ជើញក្រុមហ៊ុនកម្ពុជា ដែលកំពុងធ្វើប្រតិបត្តិការធុរកិច្ចលើគ្រប់វិស័យ ចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះដោយភាគីវៀតណាមនឹងផ្តល់ស្តង់ចំនួន២ ដោយឥតគិតថ្លៃ។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួល សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជនទូទៅដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ +៨៥៥ ៨៩ ៩១១ ១០១ / +៨៥៥ ៨៧ ៧៥៥ ៥៥១ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម **១២៦៦** ឬអ៊ីម៉ែល៖ san.phirun@moc.gov.kh / tong.rita@moc.gov.kh៕

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ៖

https://go.gov.kh/moc/o8pcsl

GO.gov.KH

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N° 0743 MOC.D/EA

Phnom Penh, 4 March 2026

# ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all traders and the public that the Vietnam Trade Promotion Agency (VIETRADE) is going to organize **"The 35th Vietnam International Trade Fair (VIETNAM EXPO 2026)"** from 8-11 April 2026 at the Vietnam Exposition Center, Hanoi City, Vietnam. The Expo is an annual event sponsored by the Ministry of Industry and Trade of Vietnam to promote export, strengthen economic cooperation, and promote collaboration between Vietnam and its partners. The organizing committee will provide two complementary standard booths free of charge to Cambodian companies from all sectors.

In this regard, the Ministry of Commerce, as a facilitator, would like to cordially invite Cambodian traders and the public who are interested in the aforementioned event to kindly register with the Department of Exhibition Affairs, General Directorate Trade Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, or officials in charge via:

Tel: +855 89 911 101 / +855 87 755 551

MOC Call Center: 1266

E-mail: san.phirun@moc.gov.kh / tong.rita@moc.gov.kh.

scan to register

GO.gov.KH

THANK YOU!

Ministry of Commerce, Lot 19-61, Russian Federation Blvd, Phum Teuk Thla,
Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

Phone/Facsimile: (855) 23 866 469